មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ការវិភាគផ្លូវច្បាប់អំពីការចោទប្រកាន់និងការឃុំខ្លួនឈ្មោះ វ៉ែន វ៉ន

ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១៦

## មូលន័យសង្ខេប

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥ មេដឹកនាំសហគមន៍ជនជាតិដើមភាគតិច និងសកម្មជនសិទ្ធិមនុស្ស ឈ្មោះ វ៉ែន វ៉ន ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅពន្ធនាគារខេត្តកោះកុង ដែលគាត់ត្រូវស្ថិតនៅក្នុងការឃុំខ្លួនមុនការជំនុំជម្រះក្តីចាប់តាំងពីពេលនោះមក។ ការជំនុំជម្រះក្តីរបស់គាត់នឹងត្រូវចាប់ផ្តើមនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០១៦ នេះ។

មុននឹងការជំនុំជម្រះក្តីរបស់គាត់ ការវិភាគផ្លូវច្បាប់នេះមានគោលបំណងពិនិត្យមើលថាតើការចោទប្រកាន់ដែលដាក់មកលើ វ៉ែន វ៉ន មានលក្ខណៈសមហេតុផលដែរឬទេ ហើយថាតើការបន្តឃុំខ្លួនគាត់មុនការជំនុំជម្រះក្តីនេះជាការត្រឹមត្រូវដែរឬទេ។ ការវិភាគផ្លូវច្បាប់នេះរួមមាន (១) បង្ហាញពីបរិបទនៃការចាប់ខ្លួននិងការចោទប្រកាន់ វ៉ែន វ៉ន (២) ផ្តល់អង្គហេតុនៃការចាប់ខ្លួន ការចោទប្រកាន់និងការឃុំខ្លួន វ៉ែន វ៉ន (៣) បង្ហាញពីទិដ្ឋភាពទូទៅនៃច្បាប់ក្នុងប្រទេសនិងសិទ្ធិមនុស្សជាមូលដ្ឋានទាក់ទងនឹងការចោទប្រកាន់ពោលគឺសេរីភាពខាងការក្នុងការបញ្ចេញមតិនិងសេរីភាពពីឃុំខ្លួនតាមទំនើងចិត្ត (ក៏ដូចជាសិទ្ធិដែលមិនចងភ្ជាប់កាតព្វកិច្ចក្នុងការការពារដីធ្លីនិងវប្បធម៌របស់ជនជាតិដើមភាគតិច) (៤) ធ្វើការវិភាគអំពីការចោទប្រកាន់ និងការអនុវត្តច្បាប់មកលើអង្គហេតុនៅពេលអង្គហេតុទាំងនោះត្រូវបានរាយការណ៍ ដោយអះអាងថាច្បាប់ត្រូវបានអនុវត្តមិនបានត្រឹមត្រូវក្រោយពីពិចារណាលើវត្តតាងដែលមាន ហើយថា សិទ្ធិរបស់ វ៉ែន វ៉ន ត្រូវបានរំលោភតាមវិធីជាច្រើន និងចុងក្រោយ (៥)សន្និដ្ឋានថាការឃុំខ្លួន វ៉ែន វ៉ន មុនការជំនុំជម្រះក្តីគឺទាំងមិនសមហេតុផលនិងខុសច្បាប់ ហើយថា វ៉ែន វ៉ន ត្រូវតែរកឃើញថា មិនជាប់ពិរុទ្ធភាពនោះទេ ប្រសិនបើគាត់ពិតជាទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយពិចារណាលើអង្គហេតុនៃករណីនេះ និងច្បាប់គ្រប់ដណ្តប់ទាំងអស់។

ការវិភាគផ្លូវច្បាប់នេះរៀបចំឡើងដើម្បីដាក់ជូនសាលាដំបូងខេត្តកោះកុង ក្នុងការជួយដល់ការជំនុំជម្រះក្តីរបស់ខ្លួនដល់ វ៉ែន វ៉ន និងក្រុមប្រឹក្សាច្បាប់របស់គាត់ ប្រើប្រាស់សម្រាប់ឯកសារយោងនៅក្នុងការការពារក្តី និងដាក់ជូនភាគីដទៃទៀតក្នុងគោលបំណងសម្រាប់ការតស៊ូមតិរបស់ខ្លួន។

ការវិភាគផ្លូវច្បាប់នេះត្រូវបានបោះពុម្ពផ្សាយដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធដែលធ្វើការដើម្បីលើកកម្ពស់និងការពារសិទ្ធិ

ប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

## ១- បរិបទ

## សិទ្ធិដីធ្លីជនជាតិដើមភាគតិចស្ថិតក្នុងភាពគំរាមកំហែង

ដីធ្លីនិងធនធានធម្មជាតិនៅកម្ពុជាគឺជាធនធានដ៏សំខាន់ដែលជាឱកាសគួរឱ្យទាក់ទាញសម្រាប់អាជីវកម្មក្នុងស្រុកនិងអន្តរជាតិ។ ក្របខ័ណ្ឌគតិយុត្តិធូររលុងធ្វើឱ្យការទទួលបានសិទ្ធិក្នុងការទាញយកធនធាននានាមានភាពងាយស្រួលនិងការល្មើសលក្ខខណ្ឌតម្រូវនៃច្បាប់ប្រឈមនឹងផលវិបាកធុនធូរតិចតួច។ ជាពិសេស អ្នកដែលងាយរងគ្រោះ និងបាត់បង់ដីដូនតារបស់ខ្លួននៅក្នុងអត្រាដ៏គួរឱ្យព្រួយបារម្ភគឺសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាដែលជាទូទៅរស់នៅតំបន់ដែលសម្បូរដោយធនធាននៅក្នុងប្រទេសនេះ។ កម្ពុជាគឺទីជំរកនៃជនជាតិដើមភាគតិចទៅដល់១៩០.០០០ នាក់ដែលស្មើនឹងប្រមាណ ១,៤ ភាគរយនៃចំនួនប្រជាជននៅកម្ពុជា។[1] តាមប្រពៃណី ប្រជាជនជនជាតិដើមភាគតិចនៅកម្ពុជាទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួនតាមរយៈការដាំដុះនៅលើដីព្រៃ ការប្រើប្រាស់បច្ចេកទេសមួយហៅថាដាំដំណាំដូរវេន ឬកសិកម្មវិលជុំ។[2] ពួកគាត់ក៏ធ្វើការប្រមាញ់សត្វព្រៃ និងប្រមូលអនុផលព្រៃឈើដូចជាផ្លែឈើ ទឹកឃ្មុំ ផ្កា ផ្សិត និងជ័រឈើ។ លើសពីនេះ ជំនឿ ប្រពៃណី និងអត្តសញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិចមានការផ្សារភ្ជាប់យ៉ាងស្អិតរមួតទៅនឹងដីធ្លីនេះ។ ដីធ្លីជាពិសេសគឺព្រៃដែលជាទីគោរពសក្ការៈដ៏សំខាន់ដល់វិញ្ញាណខ័ន្ធដូនតារបស់ពួកគេនិងអារុក្ខអារក្ខអ្នកតា។ ទំនាក់ទំនងជាមួយដូនតា និងជាមួយព្រលឹងអារុក្ខអារក្ខទាំងនេះបង្កើតបានជាអត្តសញ្ញាណនិងព្រលឹងវប្បធម៌ដ៏សំខាន់របស់សហគមន៍។ ដូច្នេះ ការកំណត់អាទិភាពលើការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធទ្រង់ទ្រាយធំ និងការផ្តល់សម្បទានដីធ្លីនៅក្នុងតំបន់ដែលជនជាតិដើមភាគតិចបានរស់នៅតាំងពីដើមមកបង្កការគំរាមកំហែងដល់ជីវភាពវប្បធម៌ និងអត្តសញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិច។

ដោយសារតែសារៈសំខាន់នៃដីធ្លីសម្រាប់ការរស់រានរបស់ពួកគាត់ សហគមន៍ជនជាតិដើមភាគតិចត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំងឱ្យធ្វើការការពារដីធ្លី និងទំនៀមទម្លាប់រស់នៅរបស់ខ្លួន។ ដូចបានរៀបរាប់លម្អិតនៅក្នុងរបាយការណ៍[3]ដែលទើបតែចេញដោយ ម.ស.ម.ក សហគមន៍ជនជាតិដើមភាគតិចប្រឈមនឹងឧបសគ្គជាច្រើននៅពេលព្យាយាមការពារដីធ្លីរបស់ខ្លួនជាផ្លូវការ តាមរយៈការចុះបញ្ជីដីធ្លីរបស់ខ្លួនក្រោមប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ពួកគាត់ត្រូវប្រកួតប្រជែងជាមួយប្រយោជន៍ពាណិជ្ជកម្មដែលពោរពេញដោយអំណាច ហើយត្រូវបំពេញតាមដំណើរការចុះបញ្ជីដ៏យូរនិងស្មុគស្មាញទៀត។ អ្វីដែលគួរឱ្យសម្គាល់ជាពិសេសនោះគឺថា វិធានការ

---

[1] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា "ជនជាតិដើមនៅកម្ពុជា" (ខែមេសា ឆ្នាំ២០០៦) http://bit.ly/21tZ1rr

[2] ក៏ហៅម្យ៉ាងទៀតថា swidden agriculture។ នេះគឺជាទម្រង់មួយនៃកសិកម្មវិលជុំ ដែលដីត្រូវបានរាន ដើម្បីធ្វើការដាំដុះ ជាទូទៅតាមរយៈការកាត់ និងការដុតរុក្ខជាតិក្នុងរយៈពេលខ្លីមួយ មុននឹងបោះបង់ចោលទៅរកកន្លែងថ្មីមួយ រហូតដល់ដីជាតិដីនោះមានឡើងវិញ។

[3] ម.ស.ម.ក ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា (របាយការណ៍) (ខែកុម្ភៈ ឆ្នាំ២០១៦) http://bit.ly/1Pa69mz

ការពារបណ្តោះអាសន្នដែលផ្តល់សុវត្ថិភាពដីធ្លីដល់សហគមន៍ជនជាតិដើម ដែលព្យាយាមចុះបញ្ជីដីធ្លីរបស់ខ្លួន មិនត្រូវបានអនុវត្តរហូតដល់ដំណាក់កាលចុងក្រោយនៃដំណើរការនោះទេ។ នេះអាចមានរយៈពេលជាច្រើនឆ្នាំ បន្ទាប់ពីពួកគាត់បានចាប់ផ្តើមដំណើរការនេះ។ ទីបំផុត នេះមានន័យថា សហគមន៍ជនជាតិដើមភាគតិចដូចជា ជនជាតិជងនៅជ្រលងភ្នំអារ៉ែង ត្រូវបានទុកឱ្យការពារដីដូនតារបស់ខ្លួនដោយខ្លួនឯងពីផលប្រយោជន៍ខាងក្រៅ ជាច្រើនឆ្នាំមុននឹងពួកគាត់អាចទទួលបានសុវត្ថិភាពដីធ្លី។ នៅពេលនៃការសរសេរអត្ថបទនេះ សហគមន៍ជនជាតិជងនៅក្នុងសហគមន៍ជ្រលងភ្នំអារ៉ែងមិនទាន់បានបញ្ចប់ដំណាក់កាលទីមួយក្នុងចំណោមដំណាក់កាល ទាំងបីនៅក្នុងដំណើរការចុះបញ្ជីប័ណ្ណកម្មសិទ្ធិសមូហភាពនោះទេ។

## ការឃាត់ឃាំងនិងបើកផ្លូវតុលាការលើសកម្មជនសិទ្ធិដីធ្លី និងអ្នកការពារសិទ្ធិមនុស្ស

ក្នុងការប្រឈមនឹងការរំលោភសិទ្ធិដីធ្លីយ៉ាងច្រើន ប្រជាសហគមន៍ដែលរងផលប៉ះពាល់នៅទូទាំងប្រទេសមានសកម្មភាពកាន់តែច្រើនដើម្បីការពារនិងទាមទារសិទ្ធិរបស់ខ្លួន។ សកម្មជនដីធ្លីដែលព្យាយាមការពារដីធ្លីរបស់ខ្លួនប្រឈមនឹងហានិភ័យធ្ងន់ធ្ងរ ដោយសាររាជរដ្ឋាភិបាលកម្ពុជា(“រដ្ឋាភិបាល”)ព្យាយាមដាក់សម្ពាធលើសកម្មភាពរបស់ពួកគាត់កាន់តែខ្លាំងឡើងៗ។ នៅឆ្នាំ ២០១៥ មានករណីជាច្រើននៃការចាប់ខ្លួននិងការចោទប្រកាន់ដែលគ្មានមូលដ្ឋានច្បាស់លាស់មកលើប្រជាសហគមន៍រងគ្រោះនិងសកម្មជនសិទ្ធិដីធ្លី។ ឧទាហរណ៍ នៅថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៦ វង្ស សុខខេងលី ជាតំណាងសហគមន៍មួយរូបមកពីខេត្តព្រះវិហារ ត្រូវបានឃុំខ្លួនដោយគ្មានការចោទប្រកាន់ដោយសារការចោទសួរ ហើយយោងតាមអភិបាលរងខេត្ត *“អប់រំ”* ទាក់ទងនឹងសកម្មភាពតវ៉ារបស់គាត់។[4] គាត់បានធ្វើការតវ៉ានៅក្នុងវិវាទដីធ្លីចំនួនពីរករណីនៅក្នុងខេត្តនេះ។ នគរបាលបានព្យាយាមបង្ខំឱ្យគាត់ចុះហត្ថលេខាលើលិខិតមួយ ដោយសន្យាថានឹងឈប់ការតវ៉ារបស់គាត់ មុននឹងសម្ពាធពីសាធារណជនបានបង្ខំឱ្យមានការដោះលែងគាត់។[5] លើសពីនេះ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ សកម្មជនសហគមន៍បីនាក់នៅខេត្តស្វាយរៀង ម្នាក់ៗត្រូវបានដាក់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ៥ ឆ្នាំ ក្រោមមាត្រា ៩៧ នៃច្បាប់ស្តីពីព្រៃឈើ ពីបទលក់ឈើតិចតួចនៅក្នុងតំបន់ដីមានវិវាទ។ ប្រជាសហគមន៍បីនាក់ធ្លាប់មានប្រវត្តិជាសកម្មជនទាក់ទងនឹងដីមានវិវាទដែលពួកគាត់អះអាងថា រដ្ឋបាលព្រៃឈើបានចូលទន្រ្ទានចាប់តាំងពីឆ្នាំ ២០០៨ មកម្លេះ។[6] ការកាប់ព្រៃឈើខុសច្បាប់ជាច្រើន ដែលប្រព្រឹត្តដោយក្រុមហ៊ុនពាណិជ្ជកម្ម និងបុគ្គលមានអំណាច នៅតែមិនមានការត្រួតពិនិត្យឱ្យបានទូលំទូលាយនៅឡើយ ទោះជាយ៉ាងណា នេះមិនមែនជារឿងចម្លែកទេនៅកម្ពុជា ដែលសកម្មជនសហគមន៍ត្រូវជាប់ពិរុទ្ធភាពពីការកាប់ដើមឈើតិចតួច ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។

---

[4] ម.ស.ម.ក ‘ការចាប់ខ្លួន វង្ស សុខខេងលី បង្ហាញពីការបន្តកាគាំរាមកំហែងរបស់នគរបាល’ (ឯកសារសង្ខេប) (ខែមករា ឆ្នាំ២០១៦) http://bit.ly/1Q8kzXP

[5] ប្រភពព័ត៌មានលេខយោង៤ ខាងលើ

[6] សែន ដាវិត អ្នកភូមិទទួលទោសជាប់ពន្ធនាគារប្រាំឆ្នាំដោយសារដើមឈើបីដើម សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០១៥ http://bit.ly/1OFj6Cd

ការបង្ក្រាបលើសកម្មភាពបែបនេះ ត្រូវបានទទួលការកត់សម្គាល់ជាពិសេសនៅខេត្តកោះកុង ដែលអង្គការការពារបរិស្ថានឈ្មោះមាតាធម្មជាតិត្រូវបានក្លាយជាគោលដៅនៃយុទ្ធនាការនៃការបង្ក្រាបយ៉ាងខ្លាំងក្លា។ អង្គការមាតាធម្មជាតិមានគោលបំណងការពារការបំផ្លាញជាលក្ខណៈប្រព័ន្ធមកលើធនធានធម្មជាតិនៅខេត្តកោះកុង ហើយបានចូលរួមក្នុងយុទ្ធនាការការពារជ្រលងភ្នំអារ៉ែង និងសហគមន៍ជនជាតិដើមភាគតិចជង ពីសំណើគម្រោងទំនប់វារីអគ្គិសនី ក្រៅពីការដឹកនាំយុទ្ធនាការប្រឆាំងនឹងការបូមខ្សាច់។ ជាលទ្ធផលនៃសកម្មភាពរបស់អង្គការមាតាធម្មជាតិ សកម្មជននិងប្រជាសហគមន៍មួយចំនួន ដែលពាក់ព័ន្ធនឹងអង្គការនេះត្រូវបានក្លាយជាគោលដៅចាប់ខ្លួន និងឃុំខ្លួន។ នៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ សហស្ថាបនិកអង្គការមាតាធម្មជាតិ លោក អាឡិច ហ្គន់ហ្សាឡេស ដាវីដសុន (Alex Gonzalez-Davidson) ត្រូវបានឃុំខ្លួន និងត្រូវបានបញ្ជូនចេញពីប្រទេស អនុលោមតាមសេចក្ដីសម្រេចរបស់ក្រសួងមហាផ្ទៃក្នុងការមិនបន្តទិដ្ឋាការរបស់គាត់។ សកម្មភាពនេះត្រូវបានធ្វើឡើង បន្ទាប់ពីការព្រមានដោយបើកចំហពីសំណាក់រដ្ឋាភិបាលថាគាត់គួរតែបញ្ឈប់សកម្មភាពរបស់ខ្លួន បើមិនដូច្នេះទេនឹងត្រូវបញ្ជូនចេញពីប្រទេស។[7] នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ សកម្មជនបីរូបត្រូវបានឃុំខ្លួន នៅពេលព្យាយាមដាក់ញត្តិមួយទៅកាន់រដ្ឋសភា ដើម្បីតវ៉ាប្រឆាំងនឹងការបូមខ្សាច់នៅ កោះកុង។ នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៥ សកម្មជនអង្គការ មាតាធម្មជាតិ បីរូបទៀតឈ្មោះ សាន ម៉ាឡា ទ្រី សុវិគា និងស៊ឹម សំណាង ត្រូវបានឃុំក្នុងពន្ធនាគារ បន្ទាប់ពីមិនបានបង្ហាញមុខ ដើម្បីធ្វើការសាកសួរនៅអធិការដ្ឋាននគរបាលស្រុក ទាក់ទងនឹងការចូលរួមរបស់ពួកគាត់នៅក្នុងការតវ៉ាដោយសន្តិភាព និងគ្មានអំពើហិង្សាប្រឆាំងនឹងការបូមខ្សាច់។[8] ពួកគាត់នៅតែជាប់ឃុំឃាំង ហើយមិនទាន់មានការកំណត់កាលបរិច្ឆេទឡើងតុលាការនៅឡើយទេ។[9]

ករណីនៃការគាបសង្កត់សកម្មជននៅក្នុងឆ្នាំ២០១៥ ដែលបានលើកឡើងខាងលើ គ្រាន់តែជាឧទាហរណ៍មួយចំនួនតូចនៃឧទាហរណ៍ជាច្រើនតែប៉ុណ្ណោះ។ ជានិន្នាការទូទៅមួយ ការធ្វើទុក្ខបុកម្នេញដោយកំណត់គោលដៅលើសកម្មជននិងអ្នកតវ៉ា ដែលព្យាយាមការពារដីធ្លីរបស់ខ្លួន បង្ហាញអំពីឥរិយាបថខ្វះការអនុគ្រោះមកលើសិទ្ធិសេរីភាពបញ្ចេញមតិពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។ ការចាប់ខ្លួនទាំងនេះ និងការចាប់ខ្លួនផ្សេងៗទៀត បំបាក់ទឹកចិត្តអ្នកផ្សេងៗទៀតពីការព្យាយាមធ្វើការតស៊ូមតិសម្រាប់សិទ្ធិដីធ្លីរបស់ខ្លួនហើយដូច្នេះរឹតបន្តឹងដល់លំហប្រជាធិបតេយ្យនៅកម្ពុជា។

**ខ៊ែន ខ៊ន ជនជាតិជង និងយុទ្ធនាការការពារដីដូនតារបស់ពួកគាត់**

---

[7] គាត ឧត្តម ម៉ៃ ទិត្យថារ៉ា Daniel Pye និង Griff Tapper "សកម្មជនដែលការពារបរិស្ថានដ៏អង់អាចត្រូវបញ្ជូនចេញពីប្រទេស" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១៥ http://bit.ly/1Rh7gUF

[8] ម.ស.ម.ក "សកម្មជនអង្គការមាតាធម្មជាតិត្រូវបានដៅមុខសញ្ញាជាថ្មី" ការចេញផ្សាយលេខពិសេស កម្រងករណីសិក្សា (ខែមករា ឆ្នាំ ២០១៦) http://bit.ly/1PLWhRw

[9] អូន ភាព "សកម្មជនអង្គការមាតាធម្មជាតិត្រូវបានសាកសួរជាថ្មីនៅមុនពេលជំនុំជម្រះក្ដី" សារព័ត៌មាន *ខេមបូឌាដេលី* ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ http://bit.ly/1JXrBME

ជ្រលងភ្នំអារ៉ែងនៅក្នុងស្រុកថ្មបាំង ខេត្តកោះកុង គឺជាតំបន់មួយដែលសំបូរដោយជីវៈចម្រុះ និងជាលំនៅនៃពូជសត្វព្រៃ ដែលជិតផុតពូជមួយចំនួន។ វាជាផ្នែកមួយនៃព្រៃអភិរក្សកណ្ដាលប្រជុំភ្នំក្រវាញនិងមានប្រជាជនរស់នៅប្រមាណ ១.៥០០ នាក់ ភាគច្រើនជាជនជាតិជង។ លោក វ៉ែន វ៉ន គឺជាតំណាងដ៏សំខាន់មួយរបស់សហគមន៍នេះ។ សហគមន៍ជង បានរស់នៅជ្រលងភ្នំអារ៉ែងជាយូរយារណាស់មកហើយ។ ទោះជាយ៉ាងណា ពួកគាត់ជាច្រើនត្រូវបានផ្លាស់ប្ដូរលំនៅក្នុងអំឡុងវិវាទរវាងខ្មែរក្រហម និងកងទ័ពដែលមានសម្ពន្ធភាពជាមួយសាធារណរដ្ឋប្រជាមានិតកម្ពុជានៅឆ្នាំ ១៩៧៩ មុននឹងត្រឡប់មកវិញនៅឆ្នាំ១៩៩៨។ ប្រជាសហគមន៍មានលិខិតដែលចេញដោយចៅសង្កាត់របស់ពួកគាត់ ដែលទទួលស្គាល់កម្មសិទ្ធិដីធ្លីរបស់ពួកគាត់ ប៉ុន្តែពួកគាត់ទាំងអស់ពុំមានប័ណ្ណកម្មសិទ្ធិដីធ្លីជាផ្លូវការនោះទេ។ លើសពីនេះ ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី ត្រូវបានរៀបចំឡើងនៅក្នុងឃុំ/សង្កាត់ទាំងបី ដែលរួមមានការទទួលស្គាល់ជាផ្លូវការនូវការប្រើប្រាស់ដីធ្លីបច្ចុប្បន្ននិងការធ្វើផែនការសម្រាប់ការប្រើប្រាស់ដីធ្លីនាពេលអនាគត។ នេះគឺជាភស្តុតាង ដែលបង្ហាញថា ការប្រើប្រាស់ដីរបស់ជនជាតិដើមមាននៅក្នុងតំបន់នេះ។

នៅឆ្នាំ ២០០៦ ក្រុមហ៊ុនឆាយណា សូតឺន ផៅវ័រ ហ្គ្រីដ (China Southern Power Grid) បានចាប់ផ្ដើមធ្វើការសិក្សាសមិទ្ធិលទ្ធភាព ដើម្បីគាំទ្រដល់ការសាងសង់ទំនប់វារីអគ្គិសនីថាមពល ១០៨ មេហ្គាវ៉ាត់នៅតំបន់នោះ ប៉ុន្តែនៅឆ្នាំ ២០១០ ត្រូវបានរាយការណ៍ថា បានលុបចោលគម្រោងវិនិយោគរបស់ខ្លួន ដោយទាញហេតុផលថានឹងមានផលប៉ះពាល់លើសង្គម និងបរិស្ថានធ្ងន់ធ្ងរ ប្រសិនបើធ្វើគម្រោងនេះ។ ក្រោយមក មានការរាយការណ៍ថា ក្រុមហ៊ុនឆាយណា ហ្គ័រដៀន កូអបភឺរេសិន (China Guodian Corporation) អនុម័តគម្រោងនេះហើយបានធ្វើការស្ទង់មតិបន្ថែមទៀតនៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១២ ប៉ុន្តែបានដកចេញនៅខែធ្នូ ឆ្នាំ ២០១៣ ដោយអះអាងថាទំនប់នេះ មិនអាចសម្រេចបានផ្នែកសេដ្ឋកិច្ចនោះទេ។ នៅខែមករា ឆ្នាំ២០១៤ ក្រុមហ៊ុន ស៊ីណូហាយដ្រូ (Sinohydro) បានកាន់កាប់គម្រោងនេះ។

នៅដើមឆ្នាំ២០១៤ ដោយមានជំនួយពីក្រុមមេធាវីមួយក្រុម ដែលផ្ដល់ជំនួយដោយឥតគិតថ្លៃ សហគមន៍នេះបានចាប់ផ្ដើមរៀបចំសម្រាប់ដំណាក់កាលដំបូងនៃដំណើរការប័ណ្ណចុះបញ្ជីដីសមូហភាពនេះ ប៉ុន្តែបញ្ហាខ្វះខាតថវិការបស់ក្រុមនេះបានធ្វើឱ្យបញ្ឈប់ដំណើរការនេះ ហើយសហគមន៍នេះនៅតែមិនទាន់បានទទួលការទទួលស្គាល់អត្តសញ្ញាណជាផ្លូវការពីក្រសួងអភិវឌ្ឍន៍ជនបទនៅឡើយទេ។ ទោះជាយ៉ាងណា ថ្មីៗនេះ ការរំពឹងទុករបស់សហគមន៍ចំពោះការទទួលបានការទទួលស្គាល់អត្តសញ្ញាណជាផ្លូវការបានកើនឡើងនៅពេលដែលការិយាល័យស្នងការជាន់ខ្ពស់សិទ្ធិមនុស្សបានបង្ហាញការចាប់អារម្មណ៍លើការគាំទ្រសហគមន៍ទាំងនេះនៅក្នុងដំណាក់កាលនៃដំណើរការប័ណ្ណចុះបញ្ជីដីសមូហភាពនេះ។ សហគមន៍នេះចង់ឱ្យរដ្ឋាភិបាលកម្ពុជាបង្កើនល្បឿននៃដំណើរការប័ណ្ណចុះបញ្ជីដីសមូហភាព ហើយលុបចោលគម្រោងទំនប់ទឹកដែលនឹងមិនត្រឹមតែបំផ្លាញជីវភាពរបស់ពួកគាត់នោះទេ តែថែមទាំងគំរាមកំហែងដល់អត្ថិភាពរបស់ពួកគាត់ជាក្រុមជនជាតិដើមភាគតិចផងដែរ។ ដូចដែលតំណាងសហគមន៍មួយរូបបានសន្និដ្ឋាន ៖ "*នៅពេលយើងត្រូវបានជម្លៀស*

*ចេញពីទីនេះ គ្រប់យ៉ាងទាក់ទងនឹងអត្តសញ្ញាណរបស់យើងនឹងបាត់បង់។ វប្បធម៌ និងប្រពៃណីរបស់យើងពឹងផ្អែកលើដី។ យើងនឹងក្លាយជាប្រជាជនខ្មែរធម្មតា ហើយយើងនឹងមិនមែនជាជនជាតិដើមទៀតទេ»។*[10]

ក្នុងការឆ្លើយតបនឹងហានិភ័យដែលបង្កឡើងដោយគម្រោងធំនេះ សហគមន៍តាមមូលដ្ឋានបានចាប់ផ្តើមយុទ្ធនាការមួយ ដើម្បីបង្ហាញការប្រឆាំងរបស់ពួកគាត់។ ប្រសិនបើត្រូវបានសាងសង់ សហគមន៍ជនជាតិដើមភាគតិចក្នុងមូលដ្ឋាននិយាយថា អាងស្តុកទឹករបស់ទំនប់ទឹកនេះនឹងជន់លិចដីនៅក្នុងតំបន់ប្រមាណ ១០.០០០ ហិចតា ដោយលិចដីដូនតារបសពួកគាត់ ព្រៃជំនឿ និងកន្លែងបញ្ចុះសព្វ និងបង្កការបំផ្លេចបំផ្លាញបរិស្ថានយ៉ាងទូលំទូលាយ។ តំបន់នេះគឺជាជំរកពពួកសត្វ ដែលរងការគំរាមកំហែងជាសកលចំនួនយ៉ាងហោចណាស់ ៣០ ប្រភេទ។[11] នៅខែមីនា ឆ្នាំ២០១៤ ប្រជាសហគមន៍មូលដ្ឋាននិងសកម្មជនបានរៀបចំការបិទផ្លូវមួយដើម្បីរាំងបុគ្គលិកក្រុមហ៊ុនស៊ីណូហាយដ្រូ កុំឱ្យទៅដល់កន្លែងទំនប់ទឹកដែលបានស្នើឡើង។ អង្គការមាតាធម្មជាតិ ក៏បានចូលរួមក្នុងការបិទផ្លូវនេះដែរ។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១៤ ការបិទផ្លូវត្រូវបានបំបែកបន្ទាប់ពីសហគមន៍នេះបានរារាំងមន្ត្រីរាជរដ្ឋាភិបាលមួយក្រុមពីការចូលទៅកាន់តំបន់នេះ។ សកម្មជនមួយចំនួនត្រូវបានចាប់ខ្លួន ប៉ុន្តែត្រូវបានលែងវិញនៅល្ងាចថ្ងៃដដែល។

ទោះបីជាមានការតវ៉ាជាបន្តបន្ទាប់ក៏ដោយ ក៏ពុំទាន់មានដំណោះស្រាយលើបញ្ហាទំនប់ទឹក ដែលបានស្នើឡើងនេះទេ។ សកម្មជន និងអ្នកនយោបាយបានស្វែងរកការធានាជាច្រើនលើកពីរដ្ឋាភិបាលកម្ពុជាថាទំនប់ទឹករបស់ក្រុមហ៊ុនស៊ីណូហាយដ្រូនឹងមិនចាប់ផ្តើមទេ ប៉ុន្តែមកដល់សព្វថ្ងៃ ពុំមានការធានាណាមួយឡើយ។ នៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៥ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកអំពីប្រធានបទទំនប់ទឹកនៅជ្រលងភ្នំអារ៉ែងដោយផ្ទាល់ ដោយហាក់ដូចជាថ្កោលទោសគម្រោងនេះថាមិនអាចទៅរួចបន្តិច និងបញ្ជាប្រជាសហគមន៍ឱ្យទទួលយកការសិក្សាដែលកំពុងបន្តមកលើតំបន់នេះបន្តិច "*សិក្សាមើលឲ្យវាច្បាស់មើល ហើយខ្ញុំមានគោលគំនិតថា ទោះបីសិក្សាច្បាស់លាស់ឬមិនច្បាស់លាស់យ៉ាងម៉េច ពីនេះដល់ឆ្នាំ ២០១៨ អត់មានទេ អត់មានឲ្យធ្វើទេ ហើយគំនិតរបស់ខ្ញុំចង់ទុកឲ្យក្មេងជាន់ក្រោយណោះ"*[12] ទោះបីជាមានការខិតខំប្រឹងប្រែងដើម្បីបញ្ចប់ការខឹងសម្បាររបស់សហគមន៍ចំពោះសំណើគម្រោងនេះក៏ដោយ កង្វះវិធានការច្បាស់លាស់មិនអាចទាក់ទាញសកម្មជនតាមមូលដ្ឋានឱ្យបោះបង់ការខិតខំរបស់ខ្លួននោះទេ។

នៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៥ នៅក្នុងលិខិតមួយបញ្ជូនមកនាយករដ្ឋមន្ត្រី ហ៊ុន សែន សមាជិកសភានៃគណបក្សសង្គ្រោះជាតិកម្ពុជាចំនួនប្រាំមួយរូប បានស្នើឱ្យបោះបង់សំណើគម្រោងទំនប់វារីអគ្គិសនីនៅជ្រលងភ្នំអារ៉ែង។ ក្នុងការឆ្លើយតបនឹងលិខិតរបស់ពួកគាត់ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានសរសេរនៅថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០១៥ ថា "*សំណើរបស់សមាជិកសភា ៦ រូបគឺដូចគ្នា វាជាករណីដូចគ្នាដែលរដ្ឋាភិបាល*

---

[10] របាយការណ៍ ម.ស.ម.ក "ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ជនជាតិដើមភាគតិចនៅកម្ពុជា" http://bit.ly/1Pa69mz

[11] ហ៊ុល រស្មី និង ហ្សមប៊ រ ភីធីរ៍ "និស្សិតមួយក្រុមសង្ឃឹមថាទេសចរអាចបញ្ឈប់គម្រោងទំនប់វារីអគ្គិសនីនៅកោះកុង" សារព័ត៌មាន *ខេមបូឌាដេលី* ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ http://bit.ly/1S6jgqW

[12] ម៉ៃ ទិត្យថារ៉ា " កុំនិយាយអំពីជ្រលងអារ៉ែង" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ http://bit.ly/1ZLQdPl

*បានឆ្លើយតបពីរលើកហើយនៅវង្វេសកា"* ប៉ុន្តែបដិសេធមិនផ្តល់ការសន្យាច្បាស់លាស់ណាមួយដើម្បីសម្រាលការព្រួយបារម្ភឡើយ។[13] ថ្មីៗនេះ នៅខែមករា ឆ្នាំ ២០១៦ លោក ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពលបានប្រកាសនៅក្នុងសន្និសីទមួយថា "*នឹងមិនមានការសាងសង់ទំនប់វារីអគ្គិសនីរហូតដល់ឆ្នាំ ២០២០"* ។ នៅពេលដែលខ្វះការប្តេជ្ញានិងភាពច្បាស់លាស់ដដែលៗបែបនេះ ពុំមានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដែលសហគមន៍នេះបន្តរៀបចំយុទ្ធនាការដើម្បីការពារជ្រលងភ្នំអារ៉ែង។

## ២- អង្គហេតុ

លោក វ៉ែន វ៉ន គឺជាតំណាងសហគមន៍មួយរូបមកពីស្រុកថ្មបាំង ខេត្តកោះកុងនៃប្រទេសកម្ពុជា។ ក្នុងនាមជាសកម្មជនបរិស្ថានមួយរូបលោក វ៉ែន វ៉ន បានចូលរួមយ៉ាងសកម្មនៅក្នុងយុទ្ធនាការអភិរក្សតំបន់អារ៉ែងនៅកោះកុង នៅពេលដែលមានសំណើសាងសង់គម្រោងទំនប់វារីអគ្គិសនីមួយ ដែលត្រូវបានស្នើឡើងដោយក្រុមហ៊ុនចិនឈ្មោះស៊ីណូហាយដ្រូ។ គម្រោងកំណែទម្រង់ដីធ្លីរបស់ ម.ស.ម.ក បានចងក្រងជីវប្រវត្តិសង្ខេបអំពីសហគមន៍ជនជាតិជងនៅជ្រលងភ្នំអារ៉ែង ដោយបង្ហាញពី វ៉ែន វ៉ន និងយុទ្ធនាការក្នុងការជួយសង្គ្រោះជ្រលងភ្នំអារ៉ែង ជាផ្នែកមួយនៃកម្រងប្រវត្តិសកម្មជនដីធ្លីរបស់ខ្លួន។[14]

ជាលទ្ធផលនៃភាពសកម្មជាបន្តបន្ទាប់របស់គាត់ វ៉ែន វ៉នត្រូវបានក្លាយជាគោលដៅនៃចំណាត់របស់តុលាការជាច្រើន មុននឹងមានការចាប់ខ្លួនគាត់នៅចុងក្រោយនេះ។ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ ២០១៥ វ៉ែន វ៉នទទួលបានដីកាកោះហៅពីតុលាការមួយពីបទ "*ឧក្រិដ្ឋកម្មព្រៃឈើ*" ដែលមិនបានបញ្ជាក់ច្បាស់លាស់[15] ទោះជាយ៉ាងណា ការបើកការជំនុំជម្រះក្តីត្រូវបានពន្យារ ហើយដីកាកោះហៅថ្មីមួយទៀតត្រូវបានចេញនៅចុងខែមីនាសម្រាប់ថ្ងៃទី ០៣ខែ មេសា ឆ្នាំ ២០១៥។[16] នៅថ្ងៃទី ០៣ ខែមេសា អាជ្ញាធរបានសាកសួរ វ៉ែន វ៉ន ចំពោះការចោទប្រកាន់ថាប្រើប្រាស់ឈើពីព្រៃការពារមកសាងសង់មជ្ឈមណ្ឌលសហគមន៍មួយកន្លែង ប៉ុន្តែក្រោយមកគាត់ត្រូវបានដោះលែងនៅថ្ងៃដដែល។

នៅខែកញ្ញា ឆ្នាំ ២០១៥ គាត់ត្រូវបានចាប់ខ្លួនម្តងទៀត ខណៈដែលកំពុងដាក់ញត្តិស្នើឱ្យដោះលែងសកម្មជនអង្គការមាតាធម្មជាតិ (អង្គការមិនមែនរដ្ឋាភិបាលផ្នែកបរិស្ថានមួយ) ដែលត្រូវបានចាប់ខ្លួនពីបទធ្វើយុទ្ធនាការប្រឆាំងនឹងសកម្មភាពបូមខ្សាច់ នៅក្នុងខេត្តកោះកុង ផងដែរ។ នៅក្នុងករណីនេះ អាជ្ញាធរបានចាប់

---

[13] ឃួន ណារិម "នាយករដ្ឋមន្ត្រីស្នើឱ្យយកតំបន់អារ៉ែងធ្វើជាតំបន់អេកូទេសចរណ៍" សារព័ត៌មាន*ខេមបូឌា ដេលី* ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ២០១៥ http://bit.ly/1P7gosQ

[14] ម.ស.ម.ក ជីវប្រវត្តិសង្ខេបរបស់សកម្មជនដីធ្លី "តំបន់អារ៉ែង ដីធ្លីរបស់ពលរដ្ឋជនជាតិដើមភាគតិចរងការគំរាមដោយទំនប់វារីអគ្គិសនី (ឆ្នាំ២០១៥) http://bit.ly/1GvNUBJ

[15] ម៉ៃ ទិត្យថារ៉ា និង Daniel Pye " សកម្មជនត្រូវបានកោះហៅដើម្បីសាកសួរពីបទល្មើស សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ http://bit.ly/1Wq3wj5

[16] ម៉ៃ ទិត្យថារ៉ា និង Alice Cuddy "សកម្មជនរារាំងមិនឱ្យសាងសង់ទំនប់តំបន់អារ៉ែងត្រូវបានកោះហៅ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៥ http://bit.ly/1JW1LrZ

ខ្លួន និងចោទសួរមនុស្សសរុបចំនួន ១៧ នាក់ រួមទាំងមន្ត្រីស៊ើបអង្កេតសិទ្ធិមនុស្សផងដែរ។ មនុស្សមួយក្រុមនេះត្រូវបានដោះលែងក្រោយមកនៅក្នុងថ្ងៃដដែល។[17]

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ ២០១៥ លោក វ៉ែន វ៉ន ត្រូវបានចាប់ខ្លួននៅប្រមាណម៉ោង ១២៖២០ នាទីថ្ងៃត្រង់ រួចត្រូវបានបញ្ជូនទៅពន្ធនាគារខេត្តកោះកុង អនុលោមតាមសេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេត លោក មិន មករា ដែលបានចោទសួរ លោក វ៉ែន វ៉ន នៅព្រឹកនោះទាក់ទងនឹងការកាន់កាប់ឈើខុសច្បាប់ ដែលបានចោទប្រកាន់ពីខាងដើម។ គាត់ត្រូវបានចោទប្រកាន់ពីបទ "*ការប្រមូលផល និង/ឬអនុផលព្រៃឈើ ដោយគ្មានការអនុញ្ញាត*" (មាត្រា ៩៨ នៃច្បាប់ស្តីពីព្រៃឈើ) និង "បទលុបបំបាត់វត្ថុតាង" (មាត្រា ៥៣៣ នៃក្រមព្រហ្មទណ្ឌ"។ ការចោទប្រកាន់ទាំងពីរនេះពាក់ព័ន្ធនឹងការសាងសង់មជ្ឈមណ្ឌលសហគមន៍តូចមួយ ដែលត្រូវបានសាងសង់រួចនៅដើមឆ្នាំ ២០១៥ ដោយមានគោលបំណងឱ្យអ្នកមកទស្សនារៀនសូត្រអំពីតំបន់នេះ និងជាកន្លែងប្រជុំមួយសម្រាប់ប្រជាសហគមន៍និងសកម្មជនតាមមូលដ្ឋាន។ ដើម្បីសាងសង់មជ្ឈមណ្ឌលសម្រាប់ភ្ញៀវមួយ ក្រុមសកម្មជនបានទិញឈើប្រមាណ ១០ ម៉ែត្រគូបនៅក្នុងតម្លៃ ១.៥០០ ដុល្លារ ដែលអាជ្ញាធរអះអាងថាទទួលបានពីអ្នកលក់តាមរយៈការកាប់ឈើខុសច្បាប់។[18] ពីមុន លោក វ៉ែន វ៉ន ធ្លាប់ត្រូវបាននាំមកចោទសួរទាក់ទងនឹងការសាងសង់មជ្ឈមណ្ឌលសហគមន៍នេះនៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ប៉ុន្តែក្រោយមកដោះលែងនៅថ្ងៃដដែល។

វ៉ែន វ៉ន អះអាងថា គាត់បានទិញឈើពីប្រជាសហគមន៍ក្នុងមូលដ្ឋាន ហើយថាសហគមន៍របស់គាត់មានសិទ្ធិស្របច្បាប់[19] ជាសហគមន៍ជនជាតិដើមមួយក្នុងការប្រមូលឈើ។ មកដល់ពេលនៃការសរសេរនេះ វ៉ែន វ៉ន នៅក្នុងពន្ធនាគារនៅឡើយ។ ការកាត់ក្តីរបស់គាត់ត្រូវបានកំណត់ចាប់ផ្តើមនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០១៦។[20]

កម្មវិធីឃ្លាំមើលដើម្បីការពារអ្នកការពារសិទ្ធិមនុស្ស (Observatory for the Protection of Human Rights Defenders) បានរិះគន់ចំពោះការឃុំខ្លួន វ៉ែន វ៉ន តាមទំនើងចិត្តជាការដាក់ទណ្ឌកម្មមួយមកលើ "សកម្មភាពសិទ្ធិមនុស្សស្របច្បាប់របស់គាត់" ហើយបានអំពាវនាវឱ្យមានការដោះលែងគាត់ភ្លាមៗ និងដោយគ្មានលក្ខខណ្ឌ។[21]

**៣- ច្បាប់**

---

17 ម៉ែ ទិត្យថារ៉ា និង Alice Cuddy "អ្នកតវ៉ានៅខេត្តកោះកុងរងការបង្ក្រាប" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ http://bit.ly/1UoqNVx

18 ឃួន ណារិម " សកម្មជននៅជ្រលងអារ៉ែងបដិសេធការកាប់ឈើខុសច្បាប់" ខេមបូឌា ដេលី ថ្ងៃទី០៣ មីនា ឆ្នាំ២០១៥ http://bit.ly/1RAM9Ne

19 ច្បាប់ស្តីពីព្រៃឈើ នស/រកម/០៨០២/០១៦ (ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២) មាត្រា៤០ http://bit.ly/1tbrB3i

20 ពេជ្រ សុធារី "មន្ត្រីស្នើសុំចូលទៅសួរសុខទុក្ខសកម្មជនខេត្តកោះកុង" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ http://bit.ly/1PRJoY5

21 អង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម និងអង្គការអាយហ្វិច (OMCT & FIDH) " កម្ពុជា ៖ ការឃុំខ្លួនតាមទំនើងចិត្ត និងការយាយីតាមផ្លូវតុលាការ បណ្តឹងសារទុក្ខជាបន្ទាន់របស់ លោក វ៉ែន វ៉ន " ការអង្កេត (ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥) http://bit.ly/1Qe9pjq

មាននិយាមសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ជាតិជាច្រើនដែលពាក់ព័ន្ធនឹងករណីនេះ។ សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងខាងជួបប្រជុំគឺមានបង្ហាញយ៉ាងច្បាស់ដោយសារតែអត្តសញ្ញាណរបស់ វ៉ែន វ៉ន ជាសកម្មជនសិទ្ធិមនុស្សមួយរូបហើយដែលបានធ្វើឱ្យទទួលបានការចាប់អារម្មណ៍ពីអាជ្ញាធរ។ ទោះជាយ៉ាងណាសិទ្ធិក្នុងការរួចផុតពីការឃុំខ្លួនតាមទំនើងចិត្ត ក៏គ្របដណ្តប់ដែរ ដោយពិចារណាអំពីការឃុំខ្លួនមុនការជំនុំជម្រះក្តីរយៈពេលយូរមកលើលោក វ៉ែន វ៉ន ។ លើសពីនេះ សិទ្ធិជនជាតិដើមភាគតិចក៏ជាកត្តាត្រូវពិចារណាដ៏សំខាន់មួយដែរ ដោយសារសិទ្ធិទាំងនេះមានឥទ្ធិពលដល់ការតស៊ូទាមទារសិទ្ធិនៅជ្រលងភ្នំអារ៉ែង និងត្រូវការពារនៅក្នុងបរិយាកាសនយោបាយបែបរឹតបន្តឹងមួយ។

អ្វីដែលត្រូវកត់សម្គាល់នោះគឺថាការការពារសិទ្ធិមនុស្សអន្តរជាតិ ត្រូវបានរួមបញ្ចូលទៅក្នុងច្បាប់កម្ពុជាដោយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ដែលចែងថា កម្ពុជាត្រូវទទួលស្គាល់ និងគោរពសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ប.ស.ស") និងកតិកាសញ្ញា និងអនុសញ្ញាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។ ដូច្នេះ ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិត្រូវអនុវត្តដោយផ្ទាល់នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដូចបានបញ្ជាក់តាមសេចក្តីសម្រេចដែលធ្វើឡើងដោយក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៅឆ្នាំ២០០៧។[22]

## សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយអន្តរជាតិ

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សគឺជាសេចក្តីថ្លែងការណ៍ជាមូលដ្ឋានអំពីសិទ្ធិមនុស្ស នៅពេលសិទ្ធិទាំងនេះអនុវត្តនៅកម្ពុជា។ សិទ្ធិជាច្រើនត្រូវបានការពារដោយ ស.ប.ស.សអនុវត្តដោយផ្ទាល់មកលើករណីនេះ។ មាត្រា ៩ នៃ ស.ប.ស.ស ការពារបុគ្គលពី *"ការចាប់ខ្លួន ការឃុំខ្លួន ឬការនិរទេសតាមទំនើងចិត្ត"* ចំណែកឯមាត្រា ១០ ផ្តល់ឱ្យបុគ្គលនូវសិទ្ធិក្នុងការទទួលបាន *"ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងជាសាធារណៈមួយ ដោយសាលាក្តីឯករាជ្យ និងអនាគតិ"*។ លើសពីនេះ មាត្រា ១៩ ការពារសិទ្ធិសេរីភាពក្នុង *"ការបញ្ចេញមតិ និងយោបល់"* និងមាត្រា ២០ ការពារ *"សិទ្ធិសេរីភាពក្នុងការប្រជុំ និងការចូលរួមប្រកបដោយសន្តិភាព"*។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅឆ្នាំ ១៩៩២ ផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតអំពីសិទ្ធិទាំងនេះ។ ការរួចផុតពីការចាប់ខ្លួនតាមទំនើងចិត្ត ត្រូវបានរៀបរាប់លម្អិតនៅក្នុងមាត្រា ៩ នៃ ក.អ.ស.ព.ន ដែលពន្យល់អំពីសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដោយចែងអំពីអង្គនីតិវិធីជំនុំជំម្រះប្រកបដោយយុត្តិធម៌ និងឯករាជ្យ។ កតិកាសញ្ញានេះអះអាងថា *"គ្មាននរណាម្នាក់ត្រូវទទួលរងការចាប់ខ្លួន ឬការឃុំខ្លួនតាមទំនើងចិត្តនោះទេ"*។ ដោយធានាថា រាល់ការឃុំខ្លួនទាំងអស់ត្រូវបានធ្វើឡើងស្របតាមច្បាប់។[23] កតិកាសញ្ញានេះតម្រូវឱ្យបុគ្គលទាំងអស់ ដែលត្រូវបានចាប់ខ្លួន បង្ហាញមុខ *"ភ្លាមៗនៅចំពោះមុខចៅក្រមមួយរូប ឬមន្ត្រីផ្សេងទៀត ដែលត្រូវបានអនុញ្ញាតដោយច្បាប់ដើម្បីប្រើប្រាស់អំណាចតុលាការ* នេះមានន័យថាបុគ្គលនានាមិនអាចត្រូវបានឃុំខ្លួនក្នុងរ

[22] ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៧

[23] ក.អ.ស.ព.ន មាត្រា ៩

យៈពេលយូរដោយគ្មានការជំនុំជម្រះក្តីនៅតុលាការឡើយ។ ទាក់ទងនឹងការជំនុំជម្រះក្តីដោយផ្ទាល់ ការជំនុំជម្រះក្តីត្រូវកើតឡើងនៅក្នុង "*ពេលសមហេតុផលមួយ*"។[24]

អ្វីដែលសំខាន់សម្រាប់ករណីបច្ចុប្បន្ននេះ ក.អ.ស.ព.ន ចែងថា " *មិនមែនជាវិធានទូទៅទេ ដែលបុគ្គលរង់ចាំការជំនុំជម្រះក្តី ត្រូវជាប់ឃុំឃាំង ប៉ុន្តែការដោះលែងត្រូវមានការធានាថា នឹងបង្ហាញមុខក្នុងការជំនុំជម្រះក្តីនៅក្នុងដំណាក់កាលណាមួយនៃអង្គនីតិវិធីជំនុំជម្រះក្តីនៅតុលាការនេះ ហើយប្រសិនបើករណីកើតឡើងសម្រាប់ការកាត់សេចក្តី*"។[25] អ្នកដែលត្រូវឃុំខ្លួន ហើយជឿថា ការឃុំខ្លួននេះត្រូវបានធ្វើឡើងដោយអយុត្តិធម៌ ក៏មានសិទ្ធិក្នុងការ "*ជំនុំជម្រះក្តីនៅចំពោះមុខតុលាការ ដើម្បីឱ្យតុលាការសម្រេចដោយគ្មានការពន្យាអំពីភាពស្របច្បាប់នៃការឃុំខ្លួនគាត់ និងការបញ្ជាឱ្យមានការដោះលែងគាត់ ប្រសិនបើការឃុំខ្លួននោះមិនស្របច្បាប់*។"[26]

ដូច្នេះ រាល់ការឃុំខ្លួនទាំងអស់ត្រូវអនុវត្តតាមនីតិវិធីច្បាប់ ហើយភាគច្រើននៃបុគ្គលដែលត្រូវបានចោទប្រកាន់មិនគួរតែត្រូវបានឃុំខ្លួនមុនការជំនុំជម្រះក្តីនោះទេ។ ដូច្នេះ ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌មួយត្រូវធ្វើឡើងសម្រាប់ការចោទប្រកាន់ទាំងអស់ ហើយត្រូវមានឱកាសសម្រាប់ការដាក់បណ្តឹងសារទុក្ខផងដែរ។ កាតព្វកិច្ចទាំងអស់នៃកាតព្វកិច្ចទាំងនេះមានករណីចាំបាច់ដល់ការពិចារណាលើករណីបច្ចុប្បន្នថាតើនីតិវិធីព្រហ្មទណ្ឌនៅកម្ពុជាត្រូវបានគោរពតាមដល់កម្រិតណា ហើយថាតើនេះបំពេញតាមលក្ខខណ្ឌតម្រូវនៃសិទ្ធិក្នុងការទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ដែរឬទេ។ សិទ្ធិទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ដល់សកម្មជននៅកម្ពុជា ដែលជាញឹកញាប់បានក្លាយជាគោលដៅនៃការធ្វើទុក្ខបុកម្នេញពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាដូចបានរៀបរាប់ពីខាងដើម។

## សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក្នុងស្រុក

រដ្ឋធម្មនុញ្ញពង្រឹងការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជា ក្រោមលិខិតូករណ៍អង្គការសហប្រជាជាតិដែលត្រូវបានរៀបរាប់ខាងលើក៏ដូចជាផ្តល់ការពាររបស់ខ្លួនដោយផ្ទាល់ផងដែរ។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញពង្រឹងការការពារប្រឆាំងនឹងការចាប់ខ្លួនតាមទំនើងចិត្ត "*ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់*"។[27] មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញធ្វើការការពារសិទ្ធិសេរីភាពក្នុងការប្រជុំរបស់ប្រជាពលរដ្ឋកម្ពុជា" *ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ*"។[28] ការការពារបន្ថែមនេះបញ្ជាក់បង្ហាញបន្ថែមទៀតអំពីសារៈសំខាន់នៃស្តង់ដារអន្តរជាតិនៅពេលបកស្រាយច្បាប់កម្ពុជា។ រដ្ឋធម្មនុញ្ញផ្តល់ឱ្យក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ តុលាការ និងសភានូវសិទ្ធិអំណាចក្នុងការបកស្រាយច្បាប់ ដោយក្រុម

---

[24] ដូចប្រភពលេខយោង ២៣ ខាងលើ

[25] ដូចប្រភពលេខយោង ២៣ ខាងលើ

[26] ក.អ.ស.ព.ន មាត្រា ៩

[27] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨

[28] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤១

ប្រឹក្សារដ្ឋធម្មនុញ្ញជាស្ថាប័នមានសិទ្ធិអំណាចខ្ពស់បំផុតក្នុងការបកស្រាយពីធម្មនុញ្ញភាពនៃច្បាប់ ទោះបីជាក្រុមប្រឹក្សានេះមិនអាចជំនុំជម្រះបណ្ដឹងឧទ្ធរណ៍លើករណីក្នុងប្រព័ន្ធតុលាការក៏ដោយ។

វ៉ែន វ៉ន មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងបទល្មើសដែលស្ថិតនៅក្នុងការសង្ស័យទាំងឡាយដែលបានចោទប្រកាន់មកលើរូបគាត់។ សិទ្ធិទាំងនេះត្រូវបានការពារក្រោមរដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧។ ក្រមនីតិវិធីព្រហ្មទណ្ឌនេះចែងនូវវិធានសម្រាប់ការពារជនជាប់ចោទនៅក្នុងប្រព័ន្ធយុត្តិធម៌ និងកំណត់នូវតួនាទី និងការទទួលខុសត្រូវរបស់ចៅក្រមនិងតួអង្គអនុវត្តច្បាប់ដទៃទៀត។

ទំនួលខុសត្រូវមួយក្នុងចំណោមទំនួសខុសត្រូវនានារបស់ប្រព័ន្ធតុលាការ គឺការទប់ស្កាត់ការដាក់ពន្ធនាគារដោយខុសច្បាប់ និងការឃុំខ្លួនមុនការជំនុំជម្រះក្ដីដោយអយុត្តិធម៌តាមរយៈការការពារសិទ្ធិក្នុងការសន្មតទុកជាមុនថាគ្មានទោសកំហុស។ សិទ្ធិនេះគឺជាគោលការណ៍ច្បាប់មូលដ្ឋានមួយ និងជាសិទ្ធិមួយ ដែលត្រូវបានការពារក្រោមច្បាប់អន្តរជាតិនិងច្បាប់កម្ពុជា។[29] ការឃុំខ្លួនបុគ្គលណាម្នាក់ មុនការជំនុំជម្រះក្ដី អាចជាការបំពានសិទ្ធិក្នុងការសន្មតទុកជាមុនថាគ្មានទោស ផ្អែកលើយុត្តិកម្មសម្រាប់ការធ្វើបែបនេះ។ ទោះបីជាពេលខ្លះ មានភាពចាំបាច់សម្រាប់តុលាការក្នុងការដាក់ឱ្យឋិតនៅក្នុងការឃុំខ្លួនមុនការជំនុំជម្រះ ដើម្បីជួយផ្ដល់យុត្តិធម៌ឱ្យបានសមរម្យ និងដើម្បីការពារជនរងគ្រោះ និងសាក្សីក៏ដោយ ក៏ការឃុំខ្លួនមុនការជំនុំជម្រះហួសហេតុប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការសន្មតទុកជាមុនថាគ្មានទោស រហូតដល់ពេលមានការចោទប្រកាន់ដោយសាលាក្ដីអនាគតិនិងមានសមត្ថកិច្ច។ ការឃុំខ្លួនមុនជំនុំជម្រះក្ដីឬបណ្ដោះអាសន្ន គួរតែប្រើប្រាស់នៅក្នុងកាលៈទេសៈតិចតួចបំផុត ដូចចែងក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៖

*"ការឃុំខ្លួនបណ្ដោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះ ជាការចាំបាច់៖*

*១- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។*

*២- ដើម្បីរារាំងកុំឱ្យមានការគាប់សង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត។*

*៣- ដើម្បីរក្សាភស្ដុតាង ឬតម្រុយជាសម្ភារៈ។*

*៤- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។*

*៥- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។*

*៦-ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស។"*[30]

ដូចបានគូសបញ្ជាក់តាមរយៈកាលៈទេសៈកម្រិតទាំងនេះ ការឃុំខ្លួនមុនការជំនុំជម្រះក្ដីគឺត្រូវប្រើប្រាស់ជាវិធីចុងក្រោយមួយ ហើយចៅក្រមគួរតែសម្រេចដោះលែងជនត្រូវចោទរហូតដល់មានការជំនុំជម្រះ ឬគួរ

[29] សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ មាត្រា១១(២)រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨
[30] ក្រមនីតិវិធីព្រហ្មទណ្ឌនៃកម្ពុជា ឆ្នាំ ២០០៧ មាត្រា ២០៥

ពិចារណាលើការដាក់ឱ្យឋិតនៅក្រោមការស៊ើបអង្កេតរបស់តុលាការ(ដាក់លក្ខខណ្ឌលើសេរីភាពរបស់បុគ្គលរហូតដល់ការជំនុំជម្រះក្តី) មុននឹងពួកគាត់ពិចារណាលើការឃុំខ្លួនមុនការជំនុំជម្រះក្តី។ លុះត្រាតែការដាក់ឱ្យឋិតនៅក្រោមការស៊ើបអង្កេតរបស់តុលាការមិនអាចឆ្លើយតបនឹងក្តីបារម្ភទាំងអស់គ្រប់គ្រាន់ទេទើបគួរពិចារណាធ្វើការឃុំខ្លួនមុនការជំនុំជម្រះក្តី។

ទោះជាយ៉ាងណា កន្លងមក កម្ពុជាមានអត្រានៃការឃុំខ្លួនមុនការជំនុំជម្រះក្តីខ្ពស់ណាស់។ ឧទាហរណ៍ នៅឆ្នាំ២០១២ នៅក្នុងអត្រា៧០% នៃការជំនុំជម្រះក្តី ដែលស៊ើបអង្កេតដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ជនជាប់ចោទត្រូវបានឃុំខ្លួនមុនការជំនុំជម្រះក្តី។[31] ក្នុងការអភិវឌ្ឍដែលអាចនឹងកើតមានចាប់តាំងពីខែមីនា ឆ្នាំ ២០១៤ មកចៅក្រមត្រូវបានតម្រូវឱ្យផ្តល់មូលហេតុលម្អិតក្នុងការបដិសេធប្រាក់ធានាជនដែលត្រូវចោទប្រកាន់ម្នាក់ជាវិធីមួយដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយចំនួនមនុស្សនៅក្នុងការឃុំខ្លួនមុនជំនុំជម្រះក្តី។[32] ប៉ុន្តែ ទោះបីជាមានលក្ខខណ្ឌតម្រូវកាន់តែតឹងរ៉ឹងក៏ដោយ បញ្ហាហាក់ដូចជាកាន់តែអាក្រក់។ ស្ថិតិរាជរដ្ឋាភិបាលលើកឡើងថា បុគ្គលដែលស្ថិតនៅក្នុងការឃុំខ្លួនមុនការជំនុំជម្រះក្តីនៅពន្ធនាគារកម្ពុជាកើនឡើងពី២៤% ទៅ ៣០% នៃចំនួនមនុស្សក្នុងពន្ធនាគារសរុបក្នុងឆមាសទី២ នៃឆ្នាំ២០១៤។[33] ទោះជាយ៉ាងណា អ្នកអង្កេតការណ៍ឯករាជ្យបានដាក់ភាគរយរហូតដល់ទៅ ៦៣.៦% ដែលជាភាគរយខ្ពស់បំផុតនៅអាស៊ីអាគ្នេយ៍។[34]

## សិទ្ធិជនជាតិដើមភាគតិចអន្តរជាតិ

ទាក់ទងនឹងសិទ្ធិជនជាតិដើមភាគតិច មានសេចក្តីថ្លែងការណ៍មួយចំនួននៅក្នុងច្បាប់អន្តរជាតិដែលការពារប្រជាពលរដ្ឋជនជាតិដើមភាគតិច។ កម្ពុជាបានបោះឆ្នោតគាំទ្រសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច នៅពេលសេចក្តីប្រកាសនេះត្រូវបានអនុម័តនៅឆ្នាំ២០០៧ ដោយរៀបរាប់អំពីសិទ្ធិជនជាតិដើមភាគតិច និងរំឭកដល់រដ្ឋអំពីកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារវប្បធម៌ជនជាតិដើមភាគតិច។ សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិចចែងអំពីសិទ្ធិក្នុងការការពារអត្តសញ្ញាណ និងស្ថាប័នជនជាតិដើមភាគតិចរបស់ខ្លួននៅក្នុងមាត្រា ៥ ថា៖

> *"ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការរក្សា និងពង្រឹងស្ថាប័ននយោបាយ ច្បាប់ សេដ្ឋកិច្ច សង្គម និងវប្បធម៌ដោយឡែករបស់ខ្លួន ហើយក៏រក្សាសិទ្ធិរបស់ខ្លួនក្នុងការចូលរួមពេញលេញក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់រដ្ឋ ប្រសិនបើពួកគាត់មានបំណងចូលរួម។"*

---

[31] ម.ស.ម.ក របាយការណ៍ប្រចាំឆមាសលើកទី៦ "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា" ខែវិច្ឆិកា ឆ្នាំ២០១២ http://bit.ly/1NPhuV4

[32] លោក Lauren Crothers "ចៅក្រមតម្រូវឱ្យពន្យល់នូវហេតុផលនៅពីក្រោយការឃុំខ្លួនមុនការជំនុំជម្រះ" សារព័ត៌មាន *ខេមបូឌា ដេលី* ថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៤ http://bit.ly/1VJXsRI

[33] អាលីស គូឌី (Alice Cuddy) និងឆាយ ចាន់ណៃដា "រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អំពាវនាវឱ្យមានតម្លាភាព និងប្រសិទ្ធភាពក្នុងការឃុំខ្លួនមុនការជំនុំជម្រះក្តី" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ http://bit.ly/1QDBfDm

[34] ដូចប្រភពព័ត៌មានលេខយោង ៣៣ ខាងលើ

មាត្រានេះមានសារៈសំខាន់ ដោយសារមាត្រានេះទទួលស្គាល់និងផ្តល់សុពលភាពដល់សិទ្ធិអំណាច និងរចនាសម្ពន្ធសង្គមរបស់ជនជាតិដើមភាគតិច។ មាត្រានេះលើកទឹកចិត្តឱ្យរដ្ឋធ្វើការគោរពបូរណភាពរបស់ក្រុមជនជាតិដើមភាគតិច និងការព្យាយាមរបស់ក្រុមទាំងនេះក្នុងការអភិរក្សវប្បធម៌របស់ខ្លួន។

លើសពីនេះ មាត្រា ២៥ នៃសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ក៏អនុម័ត និងជាពិសេសទទួលស្គាល់ទំនាក់ទំនងពិសេសរបស់សហគមន៍ជនជាតិដើមភាគតិចជាមួយដីធ្លី៖

*"ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការរក្សានិងពង្រឹងទំនាក់ទំនងវិញ្ញាណក្ខន្ធរបស់ពួកគាត់ជាមួយនឹងដីធ្លី ដែនដី ដែនទឹក និងសមុទ្រឆ្នេរ និងធនធានផ្សេងៗទៀត ដែលជាកម្មសិទ្ធិ ឬកាន់កាប់ និងប្រើប្រាស់តាមប្រពៃណីនិងក្នុងការការពារការទទួលខុសត្រូវរបស់ខ្លួនចំពោះជនជំនាន់ក្រោយក្នុងន័យនេះ។"*

មាត្រានេះគូសបញ្ជាក់អំពីទំនាក់ទំនងផ្នែកប្រពៃណី និងអត្តសញ្ញាណវប្បធម៌ ដែលសហគមន៍ជនជាតិដើមមានចំពោះដីធ្លីរបស់ពួកគាត់ និងផ្តល់ឱ្យពួកគាត់នូវសិទ្ធិក្នុងការពង្រឹងទំនាក់ទំនងនេះ។ មាត្រានេះក៏បញ្ជាក់បង្ហាញអំពីការទទួលខុសត្រូវ ដែលសហគមន៍មានមកលើជនជំនាន់ក្រោយ។ ទាំងពីរនេះគឺជាកត្តាជំរុញទឹកចិត្តសំខាន់ៗដល់ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជាក្នុងការពុះពារតវ៉ាដើម្បីសិទ្ធិដីធ្លីរបស់ពួកគាត់ រួមទាំងនៅក្នុងករណីបច្ចុប្បន្នផងដែរ។ ទោះបីជាសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ដែលជាសេចក្តីប្រកាសមហាសន្និបាតមួយ មិនចងកាតព្វកិច្ចផ្នែកច្បាប់ក៏ដោយ ក៏វា *"តំណាងឱ្យការអភិវឌ្ឍបន្តបន្ទាប់នៃនិយាមច្បាប់អន្តរជាតិ និងឆ្លុះបញ្ចាំងការប្តេជ្ញារបស់រដ្ឋក្នុងការឆ្ពោះទៅកាន់ទិសដៅមួយស្របតាមគោលការណ៍ជាក់លាក់។"*[35]

## ការចោទប្រកាន់មកលើ វ៉ែន វ៉ន

វ៉ែន វ៉ន ត្រូវបានចោទប្រកាន់ក្រោមមាត្រា ៩៨ នៃច្បាប់ស្តីពីព្រៃឈើ និងមាត្រា ៥៣៣ នៃក្រមព្រហ្មទណ្ឌ។ មាត្រា ៩៨ ដាក់ទោសលើអ្នក ដែល *"ប្រមូលផលនិងអនុផលព្រៃឈើដោយគ្មានការអនុញ្ញាត"*។[36] បុគ្គលដែលជាប់ពិរុទ្ធពីបទនេះ "ត្រូវជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ដល់ប្រាំ (៥) ឆ្នាំ និងត្រូវរងពិន័យពីដប់ (១០) លានដល់មួយរយ (១០០) លានរៀល និងការរឹបអូសភស្តុតាងទាំងអស់ជាទ្រព្យសម្បត្តិរបស់រដ្ឋ"។[37]

មាត្រា ៥៣៣ នៃក្រមព្រហ្មទណ្ឌ សំដៅលើ "បទលុបបំបាត់វត្ថុតាង" ក្នុងគោលបំណងរារាំងដល់ការស៊ើបអង្កេតឧក្រិដ្ឋកម្មមួយ។ ជាក់ស្តែង មាត្រានេះរួមមានការផ្លាស់ទីតាំង *"វត្ថុណាមួយនៅកន្លែងមានបទឧក្រិដ្ឋ ឬបទមជ្ឈិម"។ ទង្វើនេះ "អាចដាក់ទោសឱ្យជាប់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៣ (បី) ឆ្នាំ និងការពិន័យចាប់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។"*[38] ការចោទប្រកាន់

---

[35] វេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហារបស់ជនជាតិដើមភាគតិច " សំនួរដែលត្រូវបានសួរជាញឹកញាប់៖ សេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើមភាគតិច" http://bit.ly/1QNk9Wq

[36] ច្បាប់ស្តីពីព្រៃឈើ នស/រកម/០៨០២/០១៦ (៣០ កក្កដា ២០០២) មាត្រា ៩៨ http://bit.ly/1tbrB3i

[37] ក្រមព្រហ្មទណ្ឌនៃកម្ពុជា ឆ្នាំ ២០០៩ មាត្រា ៥៣៣។

[38] ដូចប្រភពលេខយោង ៣៧ ខាងលើ

ទាំងនេះនឹងត្រូវបានពិនិត្យមើល ដើម្បីកំណត់ថាតើការចោទប្រកាន់ទាំងនេះអាចអនុម័តមកលើ វ៉ែន វ៉ន ដោយយុត្តិធម៌ដែរឬទេ។ សិទ្ធិមនុស្សពាក់ព័ន្ធក៏នឹងត្រូវបានពិនិត្យមើលដែរ ដើម្បីផ្ទៀងផ្ទាត់ថាតើការចោទប្រកាន់ទាំងនេះកំពុងត្រូវបានប្រើប្រាស់ដោយប៉ះពាល់ដល់សិទ្ធិរបស់លោក វ៉ន ដែរឬទេ។

## ៤- ការវិភាគលើអង្គហេតុ និងច្បាប់

## ការចោទប្រកាន់ទីមួយ ៖ ការប្រមូលផលព្រៃឈើដោយគ្មានការអនុញ្ញាត

វ៉ែន វ៉ន អះអាងថាភាពសកម្មរបស់គាត់គឺជាបុព្វហេតុចម្បងនៃការចាប់ខ្លួន ហើយថាការចោទប្រកាន់ទាំងនេះត្រូវបានដាក់មកលើគាត់ដោយគ្មានមូលដ្ឋានច្បាស់លាស់។ បើត្រួតពិនិត្យឡើងវិញទៅលើអង្គហេតុនិងច្បាប់ ការអះអាងនេះហាក់ដូចជាមានហេតុផលដោយផ្អែកលើធាតុផ្សំមួយចំនួន។ ធាតុផ្សំទីមួយនោះគឺថា វ៉ែន វ៉ន អះអាងថា គាត់មិនបានទទួលកំណាត់ឈើដោយខ្លួនឯងទេ ប៉ុន្តែគាត់គ្រាន់តែទិញកំណាត់ឈើទាំងនេះពីសមាជិកសហគមន៍របស់គាត់តែប៉ុណ្ណោះ។ ប្រសិនបើការអះអាងនេះពិតជាត្រឹមត្រូវ នោះការចោទប្រកាន់មកលើរូបគាត់មិនមានសុពលភាពទេ។ ទីពីរ មធ្យោបាយនៃការបានកំណាត់ឈើនិងមូលហេតុនៃការយកកំណាត់ឈើនេះគឺស្របតាមច្បាប់។ ទោះបីជាលោក វ៉ែន វ៉ន ឬសមាជិកសហគមន៍ផ្សេងទៀតជាអ្នកទទួលកំណាត់ឈើនេះក៏ដោយ ក៏អ្នកទាំងពីរមានសិទ្ធិក្នុងការធ្វើដូច្នេះក្នុងនាមជាជនជាតិដើមភាគតិចក្រោមច្បាប់ក្នុងប្រទេសនិងអនុសញ្ញាអន្តរជាតិ។ ជាចុងក្រោយ ករណីរបស់គាត់សមស្របទៅនឹងនិន្នាការនៃការយាយីតាមផ្លូវតុលាការទៅលើសកម្មជនសិទ្ធិដីធ្លី ដែលមានលក្ខណៈទូលំទូលាយនៅក្នុងឆ្នាំ ២០១៥ ហើយជាពិសេសជាផ្នែកមួយនៃការបង្ក្រាបទៅលើការតស៊ូមតិនៅជ្រលងភ្នំអារ៉ែង។

វ៉ែន វ៉ន បដិសេធថាគាត់មិនបានកាប់ឈើ ដែលត្រូវបានប្រើប្រាស់នៅក្នុងការសាងសង់មជ្ឈមណ្ឌលសហគមន៍នេះដោយខ្លួនឯងទេ។ ប្រសិនបើគ្មានភស្តុតាងបញ្ជាក់ថាគាត់បានកាប់ឈើទាំងនេះទេ (ដោយមិនទៅដល់ការចោទសួរអំពីភាពស្របច្បាប់នៃសកម្មភាពនេះ) ការចោទប្រកាន់អំពីការប្រមូលផលព្រៃឈើដោយគ្មានការអនុញ្ញាតនេះគឺគ្មានមូលដ្ឋានទាល់តែសោះ។ នេះគឺដោយសារភាសានៃក្រមព្រហ្មទណ្ឌដូចបានលើកឡើងខាងលើតម្រូវឱ្យបុគ្គលកាត់ឈើដោយខ្លួនឯង ការមានកម្មសិទ្ធិ (ត្រូវបានចោទប្រកាន់) លើផលព្រៃឈើខុសច្បាប់តែមួយមិនគ្រប់គ្រាន់នោះទេ។[39] វ៉ែន វ៉ន មិនត្រូវបានចាប់ខ្លួននៅក្នុងពេលកាប់ឈើនេះទេ ប៉ុន្តែនៅក្រោយពេលដែលមជ្ឈមណ្ឌលសហគមន៍នេះត្រូវបានសាងសង់រួចហើយ។ មើលទៅហាក់ដូចជាគ្មានភស្តុតាងគាំទ្រការចោទប្រកាន់នេះក្រៅពីវត្តមានឈើឡើយ។ ការស៊ើបអង្កេតតែមួយគត់ដែលត្រូវបានធ្វើឡើងនៅក្នុងករណីនេះហាក់ដូចជាមានតែការចោទសួរលោក វ៉ែន វ៉ន តែមួយមុខគត់។ នេះមិនត្រឹមតែមានន័យថា ការចោទប្រកាន់ថាគាត់កាប់ឈើខុសច្បាប់ទំនងជាក្លែងក្លាយប៉ុណ្ណោះទេ តែថែមទាំងរារាំងគាត់ពីការត្រូវបានចោទប្រកាន់ក្រោមមាត្រានេះ ប្រសិនបើគាត់បានទទួលឈើខុសច្បាប់ពីអ្នកដទៃមែននោះ។ លក្ខខណ្ឌតម្រូវដែលជនជាប់ចោទកាត់ឈើដោយខ្លួនឯង មានន័យថា ទោះបីជាអ្នកលក់ដែល វ៉ែន វ៉ន បានទិញឈើ បានកំណាត់ឈើ

---

[39] ច្បាប់ស្តីពីព្រៃឈើ នស/រកម/០៨០២/០១៦ (៣០ កក្កដា ២០០២) មាត្រា ៩៨ http://bit.ly/1tbrB3i

ទាំងនេះដោយខុសច្បាប់ក៏ដោយ ក៏ការចោទប្រកាន់នាពេលបច្ចុប្បន្ន ក៏នៅតែមិនសមរម្យ ពីព្រោះវាមិនអាចទាក់ទងនឹង វ៉ែន រ៉ន គ្រប់គ្រាន់ឡើយ។ ដើម្បីសន្មតថា វ៉ែន រ៉ន បានប្រព្រឹត្តបទល្មើសនេះដោយគ្មានភស្តុតាង គឺជាការប្រមាថដល់ការសន្មតទុកជាមុនថាគ្មានទោស ដែលជាសិទ្ធិមនុស្សមូលដ្ឋានមួយដែលប្រជាជនកម្ពុជាទាំងអស់ទទួលបានក្រោមថាការធានាក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ។ លើសពីនេះ វ៉ែន រ៉ន អះអាងថា ទោះបីជាគាត់បានកាត់ឈើដែលគាត់មានក៏ដោយ ដូចដែលនឹងត្រូវពិភាក្សាខាងក្រោម សិទ្ធិក្នុងនាមជាជនជាតិដើមភាគតិចក្នុងការធ្វើដូច្នេះនឹងមិនតម្រូវឱ្យមានការអនុញ្ញាតឡើយ។

វ៉ែន រ៉ន ក៏អះអាងអំពីសិទ្ធិរបស់សហគមន៍របស់គាត់ក្នុងការកាត់ដើមឈើពីព្រៃសម្រាប់ប្រើប្រាស់នៅក្នុងសកម្មភាពសាងសង់តាមទំនៀមទម្លាប់។ ហេតុដូច្នេះ ទោះបីជាលើកឡើងថា គាត់ ឬប្រជាសហគមន៍ជនជាតិដើមភាគតិចម្នាក់ទៀតកាត់ដើមឈើក៏ដោយ ពុំមាននរណាម្នាក់ក្នុងចំណោមពួកគាត់ត្រូវទទួលរងការផ្តន្ទាទោសក្រោមច្បាប់នេះទេ។ ទម្លាប់អនុវត្តន៍បែបនេះមិនត្រឹមតែអនុញ្ញាតដោយច្បាប់ប៉ុណ្ណោះទេ តែថែមទាំងត្រូវបានទទួលស្គាល់ពីសារៈសំខាន់ផ្នែកប្រពៃណីនៃទម្លាប់អនុវត្តន៍នេះផង។ តាមពិតសិទ្ធិនេះត្រូវបានការពារនៅក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីព្រៃឈើដែលផ្តល់ឱ្យសហគមន៍ជនជាតិដើមភាគតិចនូវសិទ្ធិក្នុងការប្រមូលឈើ *"ដើម្បីសាងសង់ផ្ទះ ក្រោលសត្វពាហនៈ របង និងដើម្បីធ្វើឧបករណ៍កសិកម្ម"*។[40] មាត្រានេះមានគោលបំណង "ទទួលស្គាល់និងធានានូវសិទ្ធិអ្នកប្រើប្រាស់តាមប្រពៃណីរបស់ពួកគាត់ សម្រាប់គោលបំណងនៃទំនៀមទម្លាប់ប្រពៃណី ជំនឿ សាសនា និងការរស់នៅ"។ ការការពារទាំងនេះស្មើនឹងការទទួលស្គាល់អំពីភាពជាកម្មសិទ្ធិលើដីប្រពៃណីរបស់ជនជាតិដើមភាគតិចដែលមានតាំងពីមុនមក។ ច្បាប់នេះមានគោលបំណងយ៉ាងច្បាស់ក្នុងការការពារសិទ្ធិរបស់ជនជាតិដើមភាគតិចដើម្បីការពារការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់។ ការសាងសង់មជ្ឈមណ្ឌលសហគមន៍មួយអាចត្រូវបានពិចារណាយ៉ាងសមរម្យថាជាការប្រើប្រាស់ផលព្រៃឈើសម្រាប់ *"ការរស់នៅ...តាមប្រពៃណី"*។

ចំណុចនេះមានភាពរឹងមាំជាពិសេស ចាប់តាំងពីសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីជនជាតិដើមភាគតិចបានទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចដើម្បីពង្រឹងទំនាក់ទំនងរបស់ពួកគាត់ទៅនឹងដីធ្លី ដូចបានចែងក្នុងមាត្រា ២៥។ ទោះបីជាច្បាប់នេះមិនចងកាតព្វកិច្ចផ្នែកច្បាប់ក៏ដោយ ក៏ចៅក្រមគួរតែពិចារណាទៅលើសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីជនជាតិដើមភាគតិចនៅក្នុងករណីពាក់ព័ន្ធដូចករណីនេះជាដើម។ នេះមានន័យថាសិទ្ធិជនជាតិដើមភាគតិចក្នុងការអភិរក្សនិងការការពារវប្បធម៌របស់ខ្លួនគួរតែមានឥទ្ធិពលដល់ការបកស្រាយនិងការអនុវត្តច្បាប់ក្នុងប្រទេស និងលិខិតុបករណ៍អន្តរជាតិដទៃទៀត។ វ៉ែន រ៉ន កំពុងតែសាងសង់មជ្ឈមណ្ឌលសហគមន៍មិនមែនត្រឹមតែដើម្បីការពារវប្បធម៌ជនជាតិដើមភាគតិចប៉ុណ្ណោះទេ ថែមទាំងបរិស្ថានតាមមូលដ្ឋានរបស់គាត់ផងដែរ។ តាមរយៈការធានាថាភ្ញៀវមកទស្សនានិងប្រជាជនក្នុងមូលដ្ឋានមានកន្លែងរៀនសូត្រអំពីវប្បធម៌ជនជាតិដើមភាគតិច លោក វ៉ែន រ៉ន គឺកំពុងតែធ្វើអ្វីដូចនឹងទស្សនវិស័យរបស់ UNDRIP។

[40] ច្បាប់ស្តីពីព្រៃឈើ មាត្រា ៤០

## ការចោទប្រកាន់ទីពីរ ៖ ការលុបបំបាត់វត្ថុតាង

ទាក់ទងនឹងការចោទប្រកាន់អំពីបទលុបបំបាត់វត្ថុតាង នេះហាក់ដូចជាមិនសមស្របឡើយ។ ដូចបានលើកឡើងខាងដើម លោក វ៉ែន វ៉ន ត្រូវបានសាកសួរនៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ទាក់ទងនឹងការចោទប្រកាន់ទាំងនេះ ប៉ុន្តែពុំមានការចាត់វិធានការផ្សេងទៀតទេនាពេលនោះ ។ រហូតមកដល់ថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០១៥ ទើបគាត់ត្រូវបានចាប់ខ្លួនទាក់ទងនឹងការសាងសង់មជ្ឈមណ្ឌលសហគមន៍នេះ។ ប្រសិនបើភស្តុតាងដែលសំដៅលើឈើដែលត្រូវបានប្រើប្រាស់ក្នុងការសាងសង់មជ្ឈមណ្ឌលសហគមន៍នោះ ការសាងសង់នេះត្រូវបានបញ្ចប់នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥[41] ហើយនៅតែមានវត្តមាននៅពេលបច្ចុប្បន្ន។ ប្រសិនបើមជ្ឈមណ្ឌលនេះមិនទាន់បានធ្វើរួចរាល់នៅពេលចាប់ផ្តើមស៊ើបអង្កេតទេ ឈើអាចត្រូវបានដកហូតបានយ៉ាងងាយ។ ប្រសិនបើមានការសង្ស័យខ្លាំងទៅលើការប្រព្រឹត្តខុស រហូតដល់កោះហៅ វ៉ែន វ៉ន ដើម្បីមកសាកសួរនាពេលនោះ វាជារឿងសមហេតុផលដែលអាជ្ញាធរអាចនឹងរឹបអូស ឬការពារភស្តុតាងដែលសង្ស័យនោះ។ ការមិនចាប់ខ្លួន វ៉ែន វ៉ន ឬមិនរឹបអូសភស្តុតាងឱ្យបានឆាប់រហ័សនៅពេលមាន"ការសង្ស័យ"កើតឡើង បញ្ជាក់ថាអាជ្ញាធរមិនបានពិចារណាថានេះជាឧក្រិដ្ឋកម្មមួយទេឬកំណាត់ឈើខុសច្បាប់នោះទេ។ ជាថ្មីម្តងទៀត ហាក់ដូចជាពុំមានមូលដ្ឋានភស្តុតាងសមហេតុផលសម្រាប់ការចោទប្រកាន់នេះទេ។

ជាងនេះទៅទៀត វ៉ែន វ៉ន ត្រូវបានចោទប្រកាន់ក្រោមមាត្រា ៥៣៣ នៃក្រមព្រហ្មទណ្ឌ ដែលតម្រូវឱ្យជនសង្ស័យលុបបំបាត់វត្ថុតាង "ក្នុងគោលបំណងធ្វើជាឧបសគ្គដល់ការស្វែងរកឲ្យឃើញនូវការពិត"។ ប៉ុន្តែ ពុំមានភស្តុតាងណាមួយគាំទ្រដល់ការអះអាងនេះទេ។ កំណាត់ឈើដែលជាកម្មវត្ថុនៃការចោទប្រកាន់នៅតែមើលឃើញយ៉ាងច្បាស់នៅក្នុងមជ្ឈមណ្ឌលសហគមន៍បច្ចុប្បន្ន ហើយវាមិនត្រូវបានប៉ះពាល់ឬយកចេញនោះទេ។ សម្រាប់គោលបំណងរបស់វ៉ែន វ៉ន គាត់មិនមានភស្តុតាងបង្ហាញពីចេតនារារាំងដល់ដំណើរការយុត្តិធម៌ឡើយ។ គាត់បានបង្ហាញខ្លួននៅពេលសាកសួរ ហើយពុំមានភស្តុតាងបញ្ជាក់ថាគាត់បានចាត់វិធានការណាមួយដើម្បីរំខានដល់ការស៊ើបអង្កេតឡើយ។

## ការឃុំខ្លួនមុនការជំនុំជម្រះក្តី

ដើម្បីធ្វើការឃុំខ្លួនមុនការជំនុំជម្រះក្តីនៅក្នុងស្ថានភាពនេះ ដែលគ្មានភស្តុតាងថា វ៉ែន វ៉ន ពិតជាបានទទួលឈើដោយខុសច្បាប់ ឬថាគាត់បានលុបបំបាត់វត្ថុតាង គឺជាការបំពិតសេរីភាពរបស់ វ៉ែន វ៉ន តាមទំនើងចិត្ត។ ការពិតពុំមានមូលដ្ឋានណាមួយក្នុងការបង្ហាញសម្រាប់ការឃុំខ្លួនមុនការជំនុំជម្រះក្តី ដូចដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។[42]

១- *ការបង្ការបទល្មើសកុំឱ្យកើតឡើងជាថ្មី* ៖ ក្នុងការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីអាជ្ញាធរ និងត្រូវបានទទួលស្គាល់ពីសកម្មនិយមរបស់គាត់នៅក្នុងសហគមន៍ វាដូចជាមិនទំនងថា លោក វ៉ែន វ៉ន មានពាក់ព័ន្ធនឹង

---

[41] ឃួន ណារិម "សកម្មជនអារ៉ែងបដិសេធក្នុងការចោទប្រកាន់កាប់ឈើខុសច្បាប់" សារព័ត៌មានខី ខេមបូឌាដេលី ០៣ មីនា ២០១៥ http://bit.ly/1RAM9Ne

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ មាត្រា ២០៥

សកម្មភាពខុសច្បាប់ណាមួយឡើយ។ លើសពីនេះ ក្ដីបារម្ភថា វ៉ែន វ៉ន នឹងប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ជាថ្មីអាចត្រូវបានដោះស្រាយ តាមរយៈការដាក់លក្ខខណ្ឌលើការជានាសមរម្យឲ្យនៅក្រៅឃុំ និងការដាក់ឱ្យឋិតនៅក្រោមការស៊ើបអង្កេតពីតុលាការ។

២- *ការរារាំងកុំឲ្យមានការគាបសង្កត់ទៅលើសាក្សីឬជនរងគ្រោះ ៖* ពុំមានជនរងគ្រោះនៅក្នុងបទល្មើសដែលបានចោទប្រកាន់នេះទេ ហើយតាមការមើលទៅ ក៏គ្មានសាក្សីដែរ។

៣- *ការរក្សាភស្តុតាង ៖* មិនទំនងថាភស្តុតាង ដែលត្រូវបានប្រើប្រាស់រួចទៅហើយនៅក្នុងការសាងសង់មជ្ឈមណ្ឌលសហគមន៍ត្រូវការធ្វើការរក្សាការពារបន្ថែមទៀតណាស់ ហើយ វ៉ែន វ៉ន បានទិញឈើនេះដើម្បីកសាងមជ្ឈមណ្ឌលនេះ និងមិនបានបង្ហាញចេតនាក្នុងការបំផ្លាញ ឬកម្ទេចភស្តុតាងនោះទេ។

៤- *ការធានារក្សាជនត្រូវចោទ៖* ដោយហេតុផលថា វ៉ែន វ៉ន ស្មគ្រចិត្តក្នុងការបង្ហាញវត្តមានរបស់ខ្លួននៅចំពោះមុខចៅក្រមស៊ើបអង្កេតដើម្បីសាកសួរ ដោយដឹងច្បាស់ថាគាត់អាចប្រឈមនឹងការចាប់ខ្លួន ការដែលគាត់អាចនឹងមិនបង្ហាញខ្លួននៅពេលជំនុំជម្រះគឺមានលក្ខណៈតិចតួចណាស់។ លើសពីនេះ កំណត់ត្រារបស់គាត់ជាមេដឹកនាំសហគមន៍និងភាពសកម្មរបស់គាត់ ហាក់ដូចជាមិនទំនងទេដែលគាត់នឹងបោះបង់សហគមន៍របស់គាត់ ហើយប្រឈមនឹងការដាក់ពន្ធនគារ។

៥- *ការពារសន្តិសុខឱ្យជនត្រូវចោទ៖* ហាក់ដូចជាមានហានិភ័យតិចតួចណាស់ពីអង្គហេតុ និងបរិបទជុំវិញថាវ៉ែន វ៉ន នឹងត្រូវគេធ្វើបាបនៅក្នុងអំឡុងពេលមុននឹងការជំនុំជម្រះក្តីគាត់។ ក្នុងនាមជាតំណាងសហគមន៍មួយរូប ដែលតស៊ូដើម្បីសិទ្ធិដីធ្លីនៃប្រជាជនរបស់គាត់ គាត់ជាផ្នែកមួយយ៉ាងសំខាន់សម្រាប់សហគមន៍របស់គាត់ ហើយក៏មិនទំនងជារងហានិភ័យនៃការប្រើអំពើហិង្សានៅក្នុងសហគមន៍ដែរ។

៦- *ធានារក្សាសណ្តាប់ធ្នាប់សាធារណៈ ៖* មូលដ្ឋាននេះមិនគួរមានសុពលភាពចំពោះការឃុំខ្លួនរបស់ វ៉ែន វ៉ន ឡើយ ដូចមានករណីកើតឡើងកន្លងមកដូចជា ការដាក់ពន្ធនាគារសកម្មជនបរិស្ថាន និងសហគមន៍ជាជាងរក្សាសណ្តាប់ធ្នាប់សាធារណៈ។ នេះត្រូវបានបង្ហាញតាមរយៈការតវ៉ា និងការចាប់ខ្លួននានា ដែលកើតឡើងនៅក្រៅសាលាដំបូងខេត្តកោះកុង នៅខែកញ្ញា ឆ្នាំ ២០១៥។

ក្រៅពីបំពានច្បាប់ក្នុងស្រុក ការឃុំខ្លួន វ៉ែន វ៉ន ក៏បំពានស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ដែលមានសុពលភាពអនុវត្តដោយផ្ទាល់នៅក្នុងច្បាប់កម្ពុជា។ ដូចបានបង្ហាញខាងលើ ការឃុំខ្លួនមុនការជំនុំជម្រះក្តីខ្វះមូលដ្ឋានច្បាប់សមហេតុផល ហើយដូច្នេះអាចត្រូវបានចាត់ទុកថាចាប់ខ្លួនតាមទំនើងចិត្ត និងខុសច្បាប់[43] ដែលត្រូវបានហាមប្រាមនៅក្រោមកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។[44]

តាមការវាយតម្លៃលើបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធទាំងនេះ ហាក់បង្ហាញយ៉ាងច្បាស់ថាពុំមានយុត្តិកម្មសម្រាប់ការឃុំខ្លួនមុនការជំនុំជម្រះក្តីរយៈពេលវែងនេះទៅលើ វ៉ែន វ៉ន ឡើយ។ ទោះបីជាតុលាការមានសិទ្ធិ

---

[43] យោបល់ទូទៅរបស់អង្គការសហប្រជាជាតិ លេខ ៣៥ CCPR/C/GC/៣៥ (១៦ ធ្នូ ២០១៤) (១១)

[44] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយមាត្រា៩

អំណាចក្នុងការបញ្ជូនជនសង្ស័យទៅឃុំខ្លួនមុនការជំនុំជម្រះក្តីក៏ដោយ ក៏នេះគួរតែត្រូវបានធ្វើឡើងនៅក្នុងកាលៈទេសៈពិសេស ប៉ុន្តែពុំមានលក្ខណៈវិនិច្ឆ័យពាក់ព័ន្ធណាមួយមានសុពលភាពអនុវត្តនៅក្នុងករណីនេះទេ។

**៥- សេចក្តីសន្និដ្ឋាន**

ការចោទប្រកាន់ដែលដាក់មកលើសកម្មជនបរិស្ថាន វ៉ែន វ៉ន ខ្វះមូលដ្ឋានភស្តុតាងទាំងស្រុងដែលនាំឱ្យមានការសន្និដ្ឋានថាច្បាប់ត្រូវបានបកស្រាយខុសទាំងស្រុង ឬមានបំណងអនុវត្តមិនត្រឹមត្រូវមកលើ វ៉ែន វ៉ន។ ការចោទប្រកាន់ទាំងនេះមិនមានយុត្តិកម្មសមហេតុផលក្រោមច្បាប់កម្ពុជាទេ ហើយបំពានសិទ្ធិរបស់ វ៉ែន វ៉ន ក្រោមរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

លើសពីនេះ ថាតើ វ៉ែន វ៉ន បានប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ឬក៏អត់ ការវិភាគមួយនៃអង្គហេតុនៃករណីនេះ និងច្បាប់គ្របដណ្តប់ទាំងអស់នាំឱ្យមានការសន្និដ្ឋានថាការឃុំខ្លួនមុនការជំនុំជម្រះក្តីរបស់ វ៉ែន វ៉ន គឺធ្វើឡើងតាមទំនើងចិត្ត និងខុសច្បាប់ដែលបំពានសិទ្ធិរបស់គាត់ក្នុងការទទួលបានសេរីភាពនិងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ការចោទប្រកាន់រួមគ្នា ដែលដាក់មកលើ វ៉ែន វ៉ន និងការឃុំខ្លួនមុនការជំនុំជម្រះក្តីរយៈពេលវែងនេះបង្ហាញថាករណីនេះកើតឡើងក្រោមហេតុផលនយោបាយ។ ផ្អែកលើការវិភាគលើការចោទប្រកាន់ និងភស្តុតាងខាងលើ ប្រសិនបើ វ៉ែន វ៉ន ទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឯករាជ្យ គាត់នឹងត្រូវរួចផុតពីការចោទប្រកាន់ទាំងអស់ និងត្រូវបានដោះលែង។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក គង់ ពិសី មេធាវីជាន់ខ្ពស់នៃ ម.ស.ម.ក តាមរយៈទូរសព្ទលេខ +៨៥៥ (០) ១២ ៩៤៥ ៧២៥ ឬ អ៊ីម៉ែល pisey.kong@cchrcambodia.org ឬ លោក ផាត ឌឺប៊្រុន ទីប្រឹក្សាច្បាប់ នៃ ម.ស.ម.ក តាមរយៈទូរសព្ទលេខ +៨៥៥ (០) ៨៩ ៥២៦ ២១៥ ឬ អ៊ីម៉ែល pat.debrun@cchrcambodia.org។**